ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
លេខ ១៤១០/២៥ ក.អ.ក.

ថ្ងៃសុក្រ ១កើត ខែទុតិយាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥

# សេចក្តីថ្លែងការណ៍

ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើឈ្លានពានយ៉ាងគឃ្លើន និងខុសច្បាប់ដែលបង្កឡើងដោយកងកម្លាំងប្រដាប់អាវុធរបស់ឃោរជាថៃដែលបានបើកការវាយប្រហារដោយចេតនា និងគិតទុកជាមុនមកលើទីតាំងឈរជើងរបស់កងទ័ពកម្ពុជានៅតាមបណ្តោយព្រំដែនរួមមាន ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥។

យើងខ្ញុំទាំងអស់គ្នា សូមថ្កោលទោសចំពោះទង្វើឈ្លានពានទាំងកំរោលឥតញញើតរបស់កងកម្លាំងប្រដាប់អាវុធថៃដែលបានប្រើប្រាស់សព្វាវុធធន់ធ្ងន់គ្រប់ប្រភេទ ជាពិសេសការទម្លាក់គ្រាប់បែកពីលើអាកាសមកក្នុងបរិវេណប្រាសាទព្រះវិហារដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក គឺជាទង្វើមិនអាចទទួលយកបាន និងចាត់ទុកជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអធិបតេយ្យភាព បូរណភាពទឹកដីរបស់កម្ពុជា និងជាការរំលោភបំពានច្បាប់អន្តរជាតិ គោលការណ៍ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងអនុសញ្ញាអន្តរជាតិនានាស្តីពីការការពារបេតិកភណ្ឌវប្បធម៌ ហើយបានបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខសណ្តាប់ធ្នាប់ក្នុងតំបន់។

ក្នុងកាលៈទេសៈដ៏សំខាន់នេះ យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រយ៉ាងពេញទំហឹងចំពោះភាពជាអ្នកដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយចក្ខុវិស័យរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាបិតាសន្តិភាពរបស់មាតុភូមិកម្ពុជា ក្នុងការឆ្លើយតបដោយកម្លាំងប្រដាប់អាវុធដែលជាស្វ័យសិទ្ធិការពារខ្លួនស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ សំដៅធានាឱ្យបាននូវសន្តិភាព ស្ថិរភាព និងឧត្តមប្រយោជន៍ស្នូលរបស់ជាតិ និងសូមគាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុវត្តវិធានការច្បាប់ទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីស្នើសុំអន្តរាគមន៍បញ្ចប់ការឈ្លានពានរបស់កងទ័ពថៃមកលើដែនអធិបតេយ្យភាពរបស់កម្ពុជា ក៏ដូចជាការអនុវត្តវិធានការច្បាប់ទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីពន្លត់និងបញ្ចប់ជម្លោះព្រំដែននៅតំបន់ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបីផងដែរ។

ក្នុងស្មារតីផ្សារភ្ជាប់រវាងសមរភូមិមុខនិងសមរភូមិក្រោយ យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរចំពោះទឹកចិត្តវីរភាពរបស់កងទ័ពដែលកំពុងពុះពារយ៉ាងអង់អាចក្លាហានឥតរួញរាការពារបូរណភាពទឹកដីនៅតាមខ្សែបន្ទាត់ព្រំដែន និងសូមប្តេជ្ញាចិត្តគាំទ្រ និងចូលរួមដោយឥតងាករេជាមួយរាជរដ្ឋាភិបាលលើគ្រប់រូបភាពទាំងកម្លាំងកាយកម្លាំងចិត្ត ប្រាជ្ញាស្មារតី និងធនធានក្នុងស្មារតីសាមគ្គីជាតិ ឯកភាពជាតិ ដើម្បីពង្រឹងខឿនការពារសុខសន្តិភាព អធិបតេយ្យភាពជាតិ បូរណភាពទឹកដី និងទប់ស្កាត់រាល់ការឈ្លានពានពីបរទេស។

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**